# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញជាអធិបតី ក្នុងពិធីក្រុងពាលី និងបញ្ចុះបឋមសីលាសាងសង់សំណង់អគារទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម កំពស់៩ជាន់



នៅព្រឹកថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៤ នៅបរិវេណទីស្តីការក្រសួង មានរៀបចំពិធី ក្រុងពាលី និងបញ្ចុះបឋមសីលាសាងសង់សំណង់អគារទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលត្រូវសាងសង់ថ្មីមានកំពស់៩ជាន់ ក្រោមអធិបតីភាព ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានការចូលរួម ពីឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាអ្នកដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួង ព្រមទាំងតំណាងក្រុមហ៊ុនសាងសង់ជាច្រើនរូបទៀត ។







ពិធីនេះត្រូវបានរៀបចំតាមគន្លងប្រពៃណី ដោយមានមានរៀបចំអាសនៈសែនព្រេនផ្លែឈើ ផ្កាភ្ញី ភេសជ្ជៈ និងនិមន្តព្រះសង្ឃចំនួន០៤អង្គ ដើម្បីសូត្រមន្ត ប្រស់ព្រហ្ម បួងសួងសុំសេចក្តីសុខពីម្ចាស់ទឹកម្ចាស់ដី និងវត្ថុស័ក្តសិទ្ធ ជាពិសេសឱ្យដំណើរការសាងសង់សម្រេចបានប្រកបដោយជោគជ័យ សុវត្ថិភាព ទុកសម្រាប់ជាទីតាំងជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការបំពេញកិច្ចការងារប្រចាំថ្ងៃប្រកបដោយភាពសមរម្យ ។

តាមរបាយការណ៍ពីតំណាងក្រុមហ៊ុនសាងសង់ ឈ្មោះ **Daun Penh Construction Co.Ltd** បានបញ្ជាក់ថា: សំណង់អគារការិយាល័យបេតុងកំពស់៍៩ជាន់ នឹងត្រូវសាងសង់លើផ្ទៃដីសរុប ៧៣២.៦៥ ម៉ែត្រក្រឡា រួមមានតួអគារទំហំ ២០ គុណ និង៣១ ម៉ែត្រ និងផ្ទៃដីសម្រាប់ចំណតរថយន្តចំនួន ១៨ រថយន្ត ។ សំណង់អគារថ្មីនេះសាងសង់ ក្នុងកំពស់ ៤១.៣៦ ម៉ែត្រ មានបន្ទប់ទាំងអស់ចំនួន៧០បន្ទប់ ដែលរួមមាន: បន្ទប់ប្រជុំចំនួន១៦-បន្ទប់ការិយាល័យធំចំនួន ០៥បន្ទប់-

បន្ទប់ការិយាល័យចំនួន៤៩បន្ទប់និងសាលប្រជុំធំចំនួន០១ ។ ក្នុងនោះ ក៏មានបន្ទប់ទឹកចំនួន៥៨ បន្ទប់ ហើយនឹងចាប់ផ្តើមដំណើរការសាងសង់ នៅថ្ងៃទី២១ ខែ ឧសភា ឆ្នាំ២០១៤ និងត្រូវបញ្ចប់នៅថ្ងៃទី២១ ខែ ឧសភា ឆ្នាំ២០១៦ ខាងមុខ ។



មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានចាត់ទុកសំណង់អគារថ្មីនេះ ជាសមិទ្ធិផលថ្មី សម្រាប់យើងទាំងអស់គ្នា ដែលទទួលការអនុញ្ញាតសាងសង់ដោយរាជរដ្ឋាភិបាលកម្ពុជា ទុកជាចំណងដៃដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបំពេញកិច្ចការ ក្នុងទីតាំងសមរម្យ និងសុវត្ថិភាព ។ ឯកឧត្តម បានធ្វើការកោតសរសើរចំពោះក្រុមហ៊ុន **Daun Penh Construction Co.Ltd** ដែលធ្លាប់មានស្នា ដៃល្អក្នុងការងារសំណង់របស់ខ្លួន និងសង្ឃឹមថាៈក្រុមហ៊ុននឹងខិតខំសាងសង់ឱ្យស្របតាម បទដ្ឋានបច្ចេក ទេសនៃគំរូប្លង់ស្ថាបត្យកម្ម និងគ្រឿងបង្គុំសំណង់ ប្រកបដោយគុណភាព និងសម្រេចបានតាមផែនការ ។ ទោះជាយ៉ាង ឯកឧត្តម បានស្នើឱ្យក្រុមហ៊ុនសាងសង់ពន្លឿនការងាររបស់ខ្លួនឱ្យបានហើយមុនចូលឆ្នាំខ្មែរ ឆ្នាំ២០១៦ និងសូមជូនពរឱ្យបុគ្គលិក កម្មករ និងវិស្វករទាំងអស់មានសុខភាពល្អ និងទទួលបានសុវត្ថិភាពជានិច្ច ក្នុងការងាររបស់ខ្លួន ។





បន្ទាប់មកឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានអញ្ជើញ កាត់ឬសសីមា និងបញ្ចុះបឋមសិលា ព្រមទាំងប្រគេនទ័យទានដល់ព្រះសង្ឃ មុននិងឯកឧត្តមបញ្ជាគ្រឿងចក្រជានិមិត្តរូបនៃការសាងសង់អគារ ទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចាប់ពីថ្ងៃទី២១ ខែ ឧសភា ឆ្នាំ២០១៤ នេះតទៅ ។